*រាជធានីភ្នំពេញ, ថ្ងៃ ២៣ ខែ មិថុនា ឆ្នាំ ២០១៦*

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង របស់សហភាពអឺរ៉ុបសម្រាប់គាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ រវាងរាជរដ្ឋាភិបាលកម្ពុជា, សហភាពអឺរ៉ុប, និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ អន្តរជាតិស៊ុយអែត (SIDA)

រសៀលថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦ វេលាម៉ោង ៣:៣០ នាទី, នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចូលរួមជាអធិបតីក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណងសហភាពអឺរ៉ុប សម្រាប់គាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៣ រវាងរាជរដ្ឋាភិបាលកម្ពុជា, សហភាពអឺរ៉ុបដែលតំណាងដោយ ឯកឧត្តម **គ្រីស្តូហ្វ័រ ចច អេដ្គារ (Christopher George Edgar)** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញ សមត្ថភាព របស់ សហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA) តំណាងដោយលោកជំទាវ **អាណា ម៉ាចហ៊ុលហ្គាដ (Anna Maj Hultgård)** ឯកអគ្គរាជទូតស៊ុយអែតប្រចាំព្រះរាជាណាចក្រកម្ពុជា ។

ហិរញ្ញប្បទានសម្រាប់គាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងដំណាក់កាលទី ៣ ***"ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"*** នេះ មានថវិកាសរុបប្រមាណ **៣៣,១ លានអឺរ៉ូ** សម្រាប់អនុវត្តរយៈពេល ៤ ឆ្នាំ (២០១៦-២០១៩) ក្នុងនោះ÷

- ថវិកាប្រមាណ **២១ លានអឺរ៉ូ** ជាថវិកាគាំទ្រដោយផ្ទាល់ (Budget Support) ពីសហភាពអឺរ៉ុប ដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយអង្គភាព ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន ដោយផ្តោតលើ÷ (១) ការកែលម្អគុណភាពស្ថិតិជាតិ, (២) កែលម្អប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (៣) ការពង្រឹងសុក្រឹតភាពនិងតម្លាភាពថវិកានៃការផ្ទេរថវិកាទៅថ្នាក់ក្រោមជាតិ, (៤) ការពង្រឹងតម្លាភាពថវិកា, (៥) ការបង្កើនការអនុវត្តថវិកាផ្អែកលើសមិទ្ធកម្ម, (៦) ការពង្រឹងប្រសិទ្ធភាព និងមុខងារសវនកម្ម, (៧) ការពង្រឹងការប្រមូលចំណូល និង (៨) ការបង្កើនតម្លាភាពលទ្ធកម្មសាធារណៈ តាមរយៈការសម្របសម្រួលការរៀបចំ, ការអនុវត្ត, ការតាមដាន និងការត្រួតពិនិត្យដោយអគ្គលេខាធិការគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ,
- ថវិកាប្រមាណ **១២,១ លានអឺរ៉ូ** (សហភាពអឺរ៉ុប ៩ លានអឺរ៉ូ និង SIDA ៣,១ លានអឺរ៉ូ) ទៀត ជាថវិកាគាំទ្របន្ថែម (Complementary Support) ដែលអនុវត្តដោយផ្ទាល់ដោយសហភាពអឺរ៉ុប និង ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA) លើការកែលម្អគុណភាពស្ថិតិជាតិ, ពង្រឹងការប្រមូលចំណូល, កែលម្អប្រសិទ្ធភាព និងតម្លាភាពសវនកម្មឯករាជ្យ និងពង្រឹងតម្លាភាពថវិកា ដោយសហការជាមួយនឹងក្រសួងផែនការ, អាជ្ញាធរសវនកម្មជាតិ និងអង្គភាពពាក់ព័ន្ធ ។

ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី បានមានប្រសាសន៍គូសបញ្ជាក់ថា កិច្ចព្រមព្រៀងហិរញ្ញប្បទាននេះកើតចេញពីកិច្ចខិតខំប្រឹងប្រែង និងកិច្ចសហប្រតិបត្តិការរួមគ្នារវាងរាជរដ្ឋាភិបាលកម្ពុជា សហភាពអឺរ៉ុប និងប្រទេសស៊ុយអែត ដែលឆ្លុះបញ្ចាំងពីការរីកចម្រើនក្នុងកិច្ចទំនាក់ទំនង ព្រមទាំងជាសក្ខីកម្មអំពីការទទួលស្គាល់របស់សហភាពអឺរ៉ុបលើវឌ្ឍនភាពដ៏ល្អប្រសើរនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ឯកឧត្តមបណ្ឌិតទេសរដ្ឋមន្ត្រី ក៏បានថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះសហភាពអឺរ៉ុប ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA) និងដៃគូអភិវឌ្ឍន៍នានា ដែលតែងតែបន្តការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ។

ជាមួយគ្នានេះ តំណាងសហភាពអឺរ៉ុប និងតំណាងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA) បានកោតសរសើរ និងវាយតម្លៃខ្ពស់លើកិច្ចខិតខំប្រឹងប្រែង ក្នុងស្មារតីសហប្រតិបត្តិការយ៉ាងស្អិតល្មួតរបស់ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាពិសេសអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការងារសម្របសម្រួលលើការរៀបចំកិច្ចព្រមព្រៀងហិរញ្ញប្បទាន ប្រកបដោយភាពជោគជ័យ ។

ឯកឧត្តម **គ្រីស្តូហ្វ័រ ចច អេដ្គារ** (**Christopher George Edgar**) ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា ក៏បានមានប្រសាសន៍បន្ថែមថា សហភាពអឺរ៉ុប ពិតជារីករាយក្នុងការក្លាយជាផ្នែកមួយនៃគម្រោងដែលជួយគាំទ្រធ្វើឲ្យកាន់តែប្រសើរឡើង នូវតម្លាភាពនិងគណនេយ្យភាព ក្នុងការគ្រប់គ្រងថវិកាជាតិ។ ទំនាក់ទំនងដែលបានបង្កើតឡើងរវាងប្រទេសស៊ុយអែត និង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលកម្ពុជា ជាកាលានុវត្តភាពក្នុងការចែករំលែកនូវឧត្តមានុវត្តន៍ នៅក្នុងវិស័យដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍនាពេលអនាគត ដើម្បីផ្តល់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជា" ៕